


ផែនទីឥណ្ឌូចិន រៀបរៀងដោយអ្នកតំណាងរាស្ត្របារាំង ហ្វ្រង់ស្វ័រ ដឺឡុង ឆ្នាំ ១៨៨៩ ដែលយកតាមលំនាំផែនទីនានា ផ្នែកក្រសួងភូមិសាស្ត្រ នៃ កងទ័ពបារាំង នៅឥណ្ឌូចិន តាមឯកសារនានា នៃ អណ្ណាម តុងកឹង និង ថៃ ព្រមទាំងការរុករក តាមដំណើរ និង តាម បេសកកម្មនានា ដែលបានធ្វើឡើងក្នុងពេលចុងក្រោយបំផុត ។




ប្រទេសកម្ពុជា សតវត្សទី ១៦ (មុនបែក បន្ទាយលង្វែក)




ផែនទី ២

**ការវិវត្តន៍ ឧបទ្វីបឥណ្ឌូចិន ចាប់ពី ស.វ. ទី ៦**

*នៅចន្លោះ ស.វ. ទី ៦-៨ ចេនឡា ឬ ប្រទេសកម្ពុជា មានរាជាណាចក្រជិតខាង ៖*

- *ខាងកើតរាជាណាចក្រចាម្ប៉ា របស់ជនជាតិចាម បានទទួលឥទ្ធិពលពីឥណ្ឌា ដូចគ្នាចេនឡា របស់ខ្មែរដែរ ។*
- *ខាងជើងរាជាណាចក្រចាម្ប៉ា មានដៃវៀត បានទទួលឥទ្ធិពលពីចិន ។ ដៃវៀត បានចុះមកយក ចាម្ប៉ា ពី ស.វ. ទី ១០ ។*
- *ខាងជើងចេនឡា មាន ណានចៅ នៅ ស.វ. ទី ៨ ។ ថៃ ចុះមក កម្ពុជា នៅ ស.វ. ទី ១១ បង្កើត សុខោថៃ នៅ ស.វ. ទី ១៣ ។*
- *ខាងលិចមាន ទ្វារវតី ជារាជាណាចក្រមន ស.វ. ទី ៧ ដែលបានតាំងទីរស់នៅតាមវាលទំនាប ទន្លេ មេណាម ។*



# ឥណ្ឌូចិន ស្ថិតក្នុងរបបកុម្មុយនិស្ត ឆ្នាំ ១៩៧៥ ឥណ្ឌូចិន ៖ វៀតណាម លាវ កម្ពុជា បានធ្លាក់ចូលដៃ កុម្មុយនិស្តឥណ្ឌូចិន

## កុម្មុយនិស្ត ឥណ្ឌូចិន

### I. សេចក្តីសង្ខេប

*កុម្មុយនិស្តឥណ្ឌូចិននេះ ខ្លះធ្លាប់ឲ្យឈ្មោះថា ជាកុម្មុយនិស្តយួន, ខ្លះទៀតថា ជាយួនខាងជើង, ខ្លះទៀតថា ជាយៀកមិញ, ខ្លះទៀតថា ជាយៀកកុង ។ ការពិត ទាំងអស់នេះ មានតែមួយគត់ គឺកុម្មុយនិស្តដែលយើងឲ្យឈ្មោះថា "កុម្មុយនិស្តឥណ្ឌូចិន" នេះឯង ។*

*ដោយហេតុថា កុម្មុយនិស្តឥណ្ឌូចិននេះ មានឫស មានគល់ ជា "យួន" យើងតោងសិក្សា អំពីយួននេះ ក្នុងឋានៈជាជាតិសាសន៍មួយ ឲ្យបានស្គាល់បន្តិចសិន ។*

#### ១. ដើមកំណើត នៃ ជនជាតិយួន

*ជនជាតិយួន មានដើមកំណើតនៅក្នុងស្រុកចិន ម្តុំខាងត្បូងសៀងហៃ តាមទំនាប នៃទន្លេយ៉ង់សេ (YANG TS ) ។ ពួកនេះ មានឈ្មោះដើមហៅថា ណាំវៀត (NAMVIET) ឬ យូវ៉េ (YUE) ដែលខ្មែរយើងឲ្យឈ្មោះថា "យួន" ។ សាសន៍យួននេះ គ្មានជាប់ពូជអំបូរជាមួយ ខ្មែរមន ទេ ។*

*យួន ឬ វៀត (VIET) ជាជាតិពន្ធុ មាន ៨០% នៅវៀតណាមសព្វថ្ងៃ ។*

#### ២. ការរាតត្បាត នៃ ជាតិយួន មកលើ ដែនតុងកឹង

*ដែនតុងកឹង ឬ ដីទំនាបទន្លេក្រហម ដែល យួនហៅថា "បាក់គី" (BAC KY) ឬ ដែល យួនកុម្មុយនិស្តនិយម ហៅថា "បាក់បូ" (BAC BO) ជាដីរបស់កុលសម្ព័ន្ធមេវ (MEO ), ម៉ុយ (MO S), ថៃ (THAI), ម៉ន (MAN ) ។ល។*

*លុះដល់ឆ្នាំ ១១១ មុន គ.ស. ទើបជនជាតិយួន វាតទីមកលើតំបន់នេះ ។ គេតាំងធានីមួយ ឈ្មោះហៅថា ក្រុងដុងគិញ (DONG KINH ) ដែលក្រោយមក ដូរឈ្មោះថា ហាណូយ ចំណែកឯ ជនជាតិដើម ក៏នាំគ្នាភៀសខ្លួនឡើងទៅនៅលើភ្នំអស់ទៅ ។*

*តុងកឹង ឬ បាក់គី នេះ ស្ថិតនៅក្រោមការត្រួតត្រាចិន ប្រហែល ១.០០០ ឆ្នាំ គឺពី*

ឆ្នាំ ១១១ មុន គ.ស. រហូតដល់ឆ្នាំ ៩៣៩ នៃ គ.ស. ។

## ៣. ការវាតទី នៃ ជនជាតិយួន មកលើនគរចាម្ប៉ា

នគរចាម ឬ ចាម្ប៉ា នេះ លាតសន្ធឹងតាមឆ្នេរសមុទ្រចិន ចាប់តាំងពី ខេត្តក្វាងប៊ិញ (QUANG BINH PHANTHIET ) រហូតដល់ ខេត្តផាន់ធាត (QUANG PHANTHIET ) ដែលមាន ធានី ឈ្មោះ ពិជ័យ (VIJAYA) ។

ជនជាតិយួន បានដណ្ដើមយកនគរចាម្ប៉ានេះ ពីចាម បាន ក្នុងកំឡុង ពី គ.ស. ៦០៥ រហូតដល់ គ.ស. ១៤៧០ គេប្រែឈ្មោះហៅថា អណ្ណាម ឬ ដែលយួននិយមហៅថា "ទ្រុងគី" (TRUONG KY ), ពួកកុម្មុយនិស្ត ហៅថា "ទ្រុងបូ" (TRUONG BO ) ដែលមាន ធានី ឈ្មោះ ក្រុងវ៉េ (HUE) ។

ក្នុងការដណ្ដើមយកនគរចាមនេះ យួន គេប្រើមធ្យោបាយពិសេស ៣ យ៉ាង គឺ ៖

- លបជ្រៀតជ្រែកចូលតាំងទីរស់នៅ ដោយសន្តិវិធី ។
- កាលណាចូលតាំងទីបានហើយ គេនាំគ្នាធ្វើឲ្យអំណាចកណ្ដាល ឲ្យខ្សោយ ។
- អន្តរាគមន៍យោធា ។

ក្រៅពីនេះ គេមានប្រើកលឧបាយផ្សេងៗ ដូចជាសំណូកសូកប៉ាន់ ជាស្ត្រីរូបស្អាត ឬ ជាវត្ថុមានតម្លៃ ។ល។ ឧទាហរណ៍ កាលពីឆ្នាំ ១៣០៦ ស្ដេចយួន បានលើកកូនក្រមុំ ឈ្មោះ នាង ត្រាន់ (HUYEN TRAN ) ទៅថ្វាយស្ដេចចាម ឈ្មោះ ព្រះបាទ ឆេម៉ាន់ (CHEMAN ) ដែលនាំឲ្យចាមខាតបង់ខេត្តមួយយ៉ាងធំ គឺខេត្តអូលី ឯកសារខ្លះថា អូ ជាខេត្តមួយ, ឯ លី ក៏ជាខេត្តមួយដែរ ដែលយួនប្រែឈ្មោះថា ធុយ អាន ហ៉ាវ (THU AN HAO ) ។

## ៤. ការវាតត្បាត នៃ ជនជាតិយួន មកលើកម្ពុជាក្រោម

ក្នុងការដណ្ដើមយកដីខ្មែរ នៅកម្ពុជាក្រោមនេះ យួនប្រើមធ្យោបាយដូចកាលដែលវាប្រើ ដើម្បីដណ្ដើមយកនគរចាម ដូច្នេះដែរ ។ យួនបានប្រើពេលពី ឆ្នាំ ១៦១៨ ដល់ឆ្នាំ ១៩៤៩ ទើបយកកម្ពុជាក្រោមបាន ។ ដីយើងនៅកម្ពុជាក្រោម បើរាប់ទាំង កោះត្រឡាច និង កោះត្រល់ ផង មាន ២១ ខេត្ត ដែលមានឈ្មោះដូចតទៅ (តាមសៀវភៅ សង្គ្រាមនយោបាយ ១៩៧២) ៖

| | | | |
|---|---|---|---|
| ទួលតាម៉ុក | THUDAUMOT | ឡុងហោ | VINHLONG |
| ត្រពាំងស្រែកាត្រី | BIEN HAO | ព្រះត្រពាំង | TRAVINE |
| ស្រែអំបិល | BARIA | ពាម | HATIEN |



| | | | |
|---|---|---|---|
| រោងដំរី | TAYNINH | ក្រមួនសរ | RACHGIA |
| ព្រៃនគរ | SAIGON | ព្រែកឫស្សី | CANTHO |
| ដំបូកកោង | GOCONG |ឃ្លាំង | SOCTRANG |
| មេសរ | MYTHO | ពលលាវ | BACLIEU |
| កំពង់ឫស្សី | BENTRE | ទឹកខ្មៅ | CAMAU |
| មាត់ជ្រូក | CHAUDOC | កោះត្រល់ | PHU QUOC |
| ពាមបារាជ | LONGYUEN | កោះត្រឡាច | POULO CONDOR (CONG SONG) |
| ផ្សារដែក | SADEC | | |

គួរកត់សំគាល់ថា ឈ្មោះខេត្តទាំងនេះ ត្រូវបានយួន គេដូរឈ្មោះជាច្រើនលើក ជាច្រើនសា ប្រយោជន៍ដើម្បីបំបាត់ឲ្យអស់ នូវអនុស្សាវរីយ៍ទាំងឡាយរបស់ម្ចាស់ដើម ។

មកដល់ត្រង់នេះ យើងឃើញថា ក្នុងកំឡុងពេលប្រហែល ២.០០០ ឆ្នាំ ជនជាតិយួន បានដណ្ដើមយកដីគេឯងជាច្រើន គឺប្រមាណ ៣៣៤.០០០ គ.ម.² ។ ព្រឹត្តិការណ៍នេះ អ្នកប្រាជ្ញប្រវត្តិសាស្ត្រនិយម ឲ្យឈ្មោះថា "មហាដំណើរ នៃ ជនជាតិយួន ឆ្ពោះទៅទិសខាងត្បូង" ។

## ក. ចរិតលក្ខណៈ នៃ កលយុទ្ធ ប្រយុទ្ធប្រដាប់អាវុធ

**១-** គេពុំអាចយល់ថា កលយុទ្ធប្រដាប់អាវុធ នៃ ពួកកុម្មុយនិស្ត បានតាមទស្សនៈ-វិស័យយោធា សុទ្ធសាធនោះទេ ព្រោះថា កលយុទ្ធប្រដាប់អាវុធនេះ មានលក្ខណៈធម្មជាតិរបស់វា ជានយោបាយ គឺនយោបាយ នៃ ការប្រយុទ្ធតាមទ្រឹស្ដីកុម្មុយនិស្ត ។

**២- ស្ថាបនាមូលដ្ឋាន ៖** ពួកកុម្មុយនិស្ត ចាប់ផ្ដើមបំបះបំបោរកសិករនៅស្រែចំការបានហើយ គេក៏ខំប្រឹងធ្វើឲ្យមូលដ្ឋានតូចភ្លាម ហើយយកមូលដ្ឋាននេះ មកកែទម្រង់តាមទៅទៀត ដើម្បីអង្គការឃោសនារបស់គេ ។ គេបង្កើតមូលដ្ឋានតៗគ្នា ពីភូមិមួយ ទៅភូមិមួយទៀត ។ គេនិយាយថា ក្រុមយោធាកុម្មុយនិស្តនៅកន្លែងណា ការប្រែទម្រង់ដីប្រាកដជាមាន គឺធ្វើឲ្យទាល់តែអ្នកស្រុកត្រូវនៅក្នុងកណ្ដាប់ដៃទាំងអស់ ហើយគេយកកម្លាំងទ័ពនេះ មកឧបក្រសោបទីក្រុងតែមួយ ។

**៣- រៀបចំឲ្យមានសង្គ្រាមប្រជារាស្ត្រ ៖** កាលណាគេបានបង្កើតមូលដ្ឋានមាំទាំល្អហើយ គេបំពាក់អាវុធឲ្យរាស្ត្រ និង បង្ហាត់រាស្ត្រឲ្យទៅជាយុទ្ធជន មានគោលបំណងនឹងបង្កើតកងទ័ពប្រជារាស្ត្រ ។ តាម លោក យ៉ ង្វៀង យ៉ាប់ កងកម្លាំងប្រជារាស្ត្រ មានរូបមន្ត ៣ យ៉ាង គឺ ៖

- កងកម្លាំងសំខាន់ៗ មានបេសកកម្មទៅលើសមរភូមិ ទូទាំងប្រទេស
- កងកម្លាំងប្រចាំភូមិភាគ កម្លាំងបង្គោលប្រចាំភូមិភាគ
- កងប្រជាយោធាស្វ័យត្រាណ ពាក់កណ្តាលប្រដាប់អាវុធ បង្កើតផល... នាំស្បៀង... ឃោសនា ។

ក្នុងរូបមន្ត វាយកមនុស្សដែលប្រើបាន មិនថា ស្រី ឬ ប្រុស ក្មេង ឬ ចាស់ ទេ ឲ្យតែច្បាំងបាន ។

## ២. តើអ្នកណាខ្លះជា កុម្មុយនិស្តពេញលក្ខណៈ ?

បណ្តាអ្នកដឹកនាំធំៗ នៃ កុម្មុយនិស្តឥណ្ឌូចិន មានតែ ហូជិមិញ មួយគត់ ដែលជាសមាជិកពេញលក្ខណៈ នៃ អន្តរជាតិទី ៣ នៅក្រុងមូស្គូ (III[me] INTERNATINALE) ។ អ្នកដឹកនាំឯទៀតៗ សុទ្ធតែជាអ្នកជាតិនិយម (NATIONALISTES) ទាំងអស់ ។ ប៉ុន្តែ គេនាំគ្នាជ្រើសរើសយកលទ្ធិកុម្មុយនិស្តនេះ គឺដើម្បីជាមធ្យោបាយមួយ ដើម្បីសំរេច នូវគោលបំណងគេ ក្នុងការបំរើដល់ប្រយោជន៍ប្រទេសជាតិគេ តែប៉ុណ្ណោះ ។

## ៣. គោលបំណងរបស់ កុម្មុយនិស្តឥណ្ឌូចិន

ក- ទាមទារយកដឹកម្ពុជាក្រោម ដោយយកលេសថា "ឯកភាព" នៃ ជនជាតិយួន (UNIFICATION DES 3 KY)។

ខ- ទាមទារឯករាជ្យឲ្យប្រទេសយួន ។

គ- ដេញបារាំងចេញពីឥណ្ឌូចិន ។

ឃ- ត្រួតត្រាឥណ្ឌូចិនជំនួសបារាំង ក្នុងឋានៈជាយួន ។

គួរកត់សំគាល់ថា ហូជីមិញ បានដើរតួជាតំណាងប្រជាពលរដ្ឋទាំងឡាយ នៅឥណ្ឌូចិន តាំងពីឆ្នាំ ១៩១៩ ម្ល៉េះ ។ កាលណោះ ហូជិមិញ បានធ្វើញត្តិមួយ ក្នុងនាម "ឥណ្ឌូចិន" សុំចូលជួប លោក ប្រធានាធិបតី វិលសុន (WIL SON ) នៅ VERSAILLES ប្រទេសបារាំង ។

## ៤. បុព្វហេតុធំៗ ដែលនាំឱ្យយួន ជ្រើសរើសយកលទ្ធិកុម្មុយនិស្ត មកធ្វើជាមធ្យោបាយ ដើម្បីដណ្តើមយកឥណ្ឌូចិន

### *ក- បដិវត្តន៍នៅប្រទេសចិន ឆ្នាំ ១៩១១*

ដើម្បីរំលំរបបរាជានិយមនោះ អ្នកដឹកនាំបដិវត្តន៍ចិន បានហៅអ្នកជំនាញការរុស្ស៊ីជាច្រើន ឲ្យមកធ្វើការក្នុងប្រទេសរបស់គេ ។ ហូជិមិញ ក៏ត្រូវបានអង្គការអន្តរជាតិទី ៣ នៅ



ក្រុងមូស្គូ ប្រើមកឲ្យធ្វើការនេះ ក្នុងប្រទេសចិនដែរ ក្នុងឋានៈជាអ្នកបកប្រែភាសា ឲ្យអ្នកជំនាញការរុស្ស៊ី ។ អ្នកជំនាញការទាំងឡាយនោះ បានខិតខំប្រឹងប្រែងធ្វើសកម្មភាព បំរើចលនាកុម្មុយនិស្តអន្តរជាតិ យ៉ាងខ្លាំង ។ ដោយមានជំនួយពី ហូជិមិញ ផង ពួកយួន ដែលរស់នៅក្នុងប្រទេសចិន ក៏ បាក់ចិត្ត បាក់គំនិត ដោយសារ ការឃោសនារបស់អ្នកជំនាញការទាំងនោះទៅ ។

ម្យ៉ាងទៀត សមាជទី ២ នៃ អន្តរជាតិទី ៣ នៅឆ្នាំ ១៩២០ បានសំរេច ៖

- បង្កើតការិយាល័យនយោបាយរបស់កុម្មុយនិស្តមួយ នៅក្រុងសៀងហៃ នៃ ប្រទេសចិន ដើម្បីងាយនឹងផ្តល់ជំនួយគ្រប់បែបយ៉ាង ចំពោះកុម្មុយនិស្តអាស៊ី ។
- "ជួយរំដោះ" ប្រទេសទាំងអស់ក្នុងលោក ឲ្យផុតពីអាណានិគមនិយមចាស់ ។
- គាំទ្រចលនាស្នេហាជាតិទាំងអស់ក្នុងលោក ។

### *ខ- ព្រឹត្តិកាល នៃ កុម្មុយនិស្តចិន*

គណបក្សកុម្មុយនិស្តចិន បានចាប់កំណើត នៅឆ្នាំ ១៩២១ ។ ពួកនេះ ដណ្តើមអំណាចពីលោក ជាង កាយជៀក បាន នៅឆ្នាំ ១៩៤៩ ។ ចាប់តាំងពីពេលនោះមក កុម្មុយនិស្តចិន បានក្លាយទៅជាបង្អែកមួយយ៉ាងមាំបំផុត សំរាប់កុម្មុយនិស្ត យួន ឬ ឥណ្ឌូចិន ។ ជំនួយខាងសម្ភារៈ គ្រប់បែបយ៉ាង មកពីរុស្ស៊ីក្តី មកពីចិនក្តី មកពីប្រទេសកុម្មុយនិស្តឯទៀតៗក្តី ត្រូវដឹកកាត់ប្រទេសចិនទាំងអស់ ។ មិនតែប៉ុណ្ណោះ ជ័យជំនះរបស់ ម៉ៅ សេទុង នេះ បានទៅជា បង្អែកខាងចិត្តសាស្ត្រមួយយ៉ាងធំរបស់ ហូជីមិញ ។

### *គ- រណសិរ្សប្រជាមានិត នៃ ប្រទេសបារាំង របស់ ឡេអុង ព្លុម*

នៅឆ្នាំ ១៩៣៦ ពួកកុម្មុយនិស្តបារាំង បានឡើងកាន់អំណាចនៅប្រទេសបារាំង ក្រោមការដឹកនាំរបស់ ឡេអុង ព្លុម ។ ក្នុងឋានៈជាកុម្មុយនិស្តដូចគ្នា រណសិរ្សប្រជាមានិតរបស់ ឡេអុង ព្លុម បានជួយជ្រោមជ្រែងកុម្មុយនិស្តឥណ្ឌូចិនរបស់ ហូជិមិញ យ៉ាងច្រើន ។

### *ឃ- កត្តា ហូជិមិញ*

កត្តាមួយ ដែលធំជាងគេ ក្នុងការដែលធ្វើឲ្យកុម្មុយនិស្តឥណ្ឌូចិន មានជីវិតរហូតដល់សព្វថ្ងៃនេះ គឺការប្រឹងប្រែងរបស់ ហូជីមិញ នេះឯងតែម្តង ។ តទៅនេះ ជាជីវប្រវត្តិសង្ខេបរបស់ ហូជីមិញ ៖ ហូជីមិញ ជាកូនអ្នកចេះដឹងម្នាក់ នៅតំបន់តុងកឹង ។ គាត់ មិនបានរៀនសូត្រអ្វីជ្រៅជ្រះទេ ។ ចាប់តាំងពីអាយុពេញវ័យមក គាត់ធ្វើជា "បោយ" នៅក្នុងកប៉ាល់ជំនួញមួយ នៃ ក្រុមហ៊ុន " MESSAGERIES MARITIMES " ដែលរត់ផ្លូវ ពីចុងបូព៌ា ទៅទ្វីបអឺរ៉ុប និង ពីអឺរ៉ុប ទៅអាមេរិកឡាទីន... ។ បន្ទាប់មក

គាត់ទៅធ្វើបោយនៅភោជនីយដ្ឋានមួយ នៅ ក្រុងឡុងដ៏ ។ ពេលសង្គ្រាមលោកលើកទី ១ គាត់រត់ទៅនៅក្រុងប៉ារីស៏ ។ នៅឆ្នាំ ១៩២០ គាត់ ចូលជាសមាជិក នៃ អន្តរជាតិទី ៣ នៅក្រុងមូស្គូ ។ ចាប់តាំងពីពេលនោះមក ហូជីមិញ ធ្វើនយោបាយរហូតដល់ស្លាប់ (សូមអានអត្ថបទ កំណើតកុម្មុយនិស្តឥណ្ឌូចិន) ។

## II. ប្រវត្តិសង្ខេប នៃ គណបក្សកុម្មុយនិស្តឥណ្ឌូចិន

### ១- សមាគម យុវជនបដិវត្តន៍យួន

ហូជីមិញ ដែលកាលណោះ មានឈ្មោះថា ង្វៀង អៃកុក នៅឡើយ បានដឹកនាំអ្នកស្នេហាជាតិយួន ដើម្បីបង្កើត នូវសមាគមនេះឡើង នៅក្រុងកង់តុង ក្នុងប្រទេសចិន ក្នុង គ.ស. ១៩២៥ ។ សមាគមនេះ បង្កើតឡើងក្នុងគោលបំណង អប់រំជនជាតិយួន ឲ្យមានស្មារតីជាតិនិយម ។ សមាជិកសំខាន់ៗ ដែលបង្កើតសមាគមនេះ គឺ ហូ ជីមិញ, ហូ ទុងម៉ៅឡៃ, ហុង ជុង, ហុង សុង, ផាំ វ៉ាន់ដុង ។ល។ អង្គការដែលសំខាន់ជាងគេ របស់សមាគមនេះ គឺ ទស្សនាវដ្ដីមួយឈ្មោះ "យុវជន" (THANH NIEN ) ។ នៅឆ្នាំដដែល នេះ ពួកអ្នកស្នេហាជាតិទាំងឡាយ ដែលទើបនឹងចេញពីកោះត្រឡាច បានបង្កើត គណបក្សមួយឈ្មោះ គណបក្សបដិវត្តន៍ នៃ យួនថ្មី ក្រោយមក គណបក្សនេះ ដោយមាន បំណងដូច ហូជីមិញ ក៏ចូលជាសមាជិក នៃ សមាគមយុវជនបដិវត្តន៍យួនទៅ ។

លុះដល់ឆ្នាំ ១៩២៧ លោក ចាង កៃឆែក បានដេញពួកអ្នកជំនាញការរុស្ស៊ី ហើយនិង ហូជីមិញ ឲ្យទៅមូស្គូវិញ ។ សមាជិកសំខាន់ៗខ្លះទៀត ត្រូវពួកចិនចាប់បាន ហើយដាក់គុក ។

ដល់ឆ្នាំ ១៩២៩ ហុង សុង ដែលជាអ្នកទទួលខុសត្រូវចំពោះសមាគម ជំនួស ហូជីមិញ បានកោះប្រជុំសមាជិកដែលនៅសល់ទាំងប៉ុន្មាន នៅក្រុងហុងកុង ។ សមាគមនេះ ក៏ត្រូវរលាយនៅពេលនោះទៅ ។ សមាជិកទាំងប៉ុន្មាន បែកគ្នាជា ៣ ពួក ហើយបង្កើត គណបក្ស ៣ ។

### ២. គណបក្ស កុម្មុយនិស្តឥណ្ឌូចិន

គណបក្សនេះ កើតឡើងនៅ ខែ មិថុនា ១៩២៩ ។ សមាជិកភាគច្រើន មកពីសមាគមយុវជនបដិវត្តន៍យួន ខ្លះទៀត មកពីគណបក្សយួនថ្មី ខ្លះទៀត មកពីសមាគមឥណ្ឌូចិន របស់ ង្វៀង អាននិញ ។



### ៣. គណបក្ស កុម្មុយនិស្តអណ្ណាមីត

គណបក្សកុម្មុយនិស្តអណ្ណាមីតនេះ កើតឡើងកាលពី ខែ តុលា ១៩២៩ អ្នកដែលបង្កើត គ្មានគោលបំណងនយោបាយធំដុំទេ ។ គឺគ្រាន់តែ ដើម្បីដេញជើងគណបក្សកុម្មុយនិស្តឥណ្ឌូចិន តែប៉ុណ្ណោះ ។

### ៤. សហភាព កុម្មុយនិស្តឥណ្ឌូចិន

គណបក្សនេះ កើតនៅ ខែ មករា ១៩៣០ ។ អ្នកដែលបង្កើត គឺ ភាគច្រើន ជាសមាជិក ឆ្វេងនិយម នៃ គណបក្សយួនថ្មី ។ គោលបំណងរបស់គេ មិនខុសពីគោលបំណងរបស់គណបក្សកុម្មុយនិស្តឥណ្ឌូចិនខាងលើនេះ ប៉ុន្មានទេ ។ សមាជិក នៃ គណបក្សនេះ ច្រើនតែជាបញ្ញវន្ត ដែលទទួល វប្បធម៌ និង អរ្យធម៌ បារាំងសែស ។ អ្នកដែលខំខ្នះខ្នែងជាងគេគឺ ដាង ថៃម៉ៃ, យ៉ ង្វៀងយ៉ាប់ ។ល។

### ៥. គណបក្ស កុម្មុយនិស្តយួន

ដំណឹងបាក់បែកគ្នានេះ បានឮទៅដល់ ង្វៀង អៃកុក ។ ពេលនោះ ង្វៀង អៃកុក ឬ ហូ ជីមិញ នេះ ពួនសម្ងំនៅប្រទេសសៀម ។ គាត់ក៏កោះប្រជុំសមាជិកធំៗ នៃ គណបក្សទាំង ៣ ដែលទើបនឹងបង្កើតនេះ នៅក្រុងហុងកុង កាលពីខែ កុម្ភៈ ១៩៣០ ។ ពេលនោះ គាត់ បានសម្រុះសម្រួលសមាជិកធំៗ នៃ គណបក្សទាំង ៣ នេះ ឲ្យលុបគណបក្សរបស់ខ្លួនចោលទាំងអស់ ហើយគាត់បង្កើតគណបក្សថ្មីមួយ ជំនួសវិញ ។ គណបក្សថ្មីនេះ មានឈ្មោះថា គណបក្សកុម្មុយនិស្តយួន ដែលមានទីស្នាក់ការនៅក្រុងហៃហ្វុង ។

### ៦. គណបក្ស កុម្មុយនិស្តឥណ្ឌូចិន

ដើម្បី ឲ្យសំរេចគោលបំណងរបស់គេ ដែលចង់ត្រួតត្រា ឥណ្ឌូចិនទាំងមូលនោះ ង្វៀង អៃកុក ក៏សម្រេចចិត្ត ជាមួយនឹងសហការីជំនិតៗខ្លះ ដូចជា ផាំ វ៉ាន់ដុង, យ៉ ង្វៀងយ៉ាប់, ដាង ថៃម៉ៃ ជាដើម ដូរឈ្មោះ គណបក្សកុម្មុយនិស្តយួន មកជា គណបក្សកុម្មុយនិស្តឥណ្ឌូចិនវិញ ក្នុងខែ មេសា ១៩៣០ ។ ការប្រែឈ្មោះនេះ មានន័យវែងឆ្ងាយណាស់ ។ គេអាចធ្វើសកម្មភាពពេញប្រទេសទាំងឡាយ នៃ ឥណ្ឌូចិននេះឯង ។

គណបក្សកុម្មុយនិស្តឥណ្ឌូចិន ក្រោយនេះ ត្រូវបានអន្តរជាតិទី ៣ ទទួលស្គាល់ កាលពីឆ្នាំ ១៩៣១ ។ ពេលនោះ គណបក្ស មានសមាជិកសកម្ម ជាង ១.៥០០ នាក់ ។

នៅរវាង ឆ្នាំ ១៩៣០ នៅក្នុងពិភពលោកទាំងមូល មានវិបត្តិសេដ្ឋកិច្ច យ៉ាងធ្ងន់ធ្ងរបំផុត ។ ឆ្លៀតពេលដែលមានវិបត្តិយ៉ាងខ្លាំងនេះ គណបក្សកុម្មុយនិស្តឥណ្ឌូចិន ក៏សំរេច

ធ្វើសកម្មភាពយ៉ាងខ្លាំង ដែលគេឲ្យឈ្មោះថា "ចលនាសូវៀត" នៅ ខេត្តង៉ែអាន ដែលជាខេត្តកំណើត របស់ ហូ ជីមិញ ។ ប៉ុន្តែ ចលនានោះ ត្រូវបានទ័ពបារាំងបង្ក្រាបវិញ យ៉ាងសាហាវ ។ សមាជិកគណៈកម្មការកណ្តាល នៃ គណបក្សនៅព្រៃនគរ ត្រូវបារាំងរកឃើញ ហើយក៏ចាប់យកទៅដាក់គុកនៅកោះត្រឡាច ឬ នៅលើភ្នំបាមីធ្លក ។ ម្យ៉ាងទៀត ង្វៀង អៃកុក ដែលជាបង្គោលយ៉ាងមាំ របស់គណបក្ស បានលួចរត់ទៅស្រុកចិន ដែលអង់គ្លេស ចាប់បាននៅក្រុងហុងកុង នៅឆ្នាំ ១៩៣១ ហើយដាក់គុកនៅទីនោះទៅ ។ ដូច្នេះ ពេលនោះ យើងឃើញថា គណបក្សកុម្មុយនិស្តឥណ្ឌូចិន ស្ទើរតែរលាយរូប ។

### ៧. គណបក្ស ជំទាស់ពេញច្បាប់

ការពិត គណបក្សកុម្មុយនិស្តឥណ្ឌូចិននេះ មិនរលាយទេ ។ ដើម្បីបន្តសកម្មភាពទៅតាមកម្លាំងរបស់ខ្លួន សមាជិកខ្លះ ដែលនៅសល់ ពិសេស ត្រាន់ វ៉ាន់គ្នោវ បានបង្កើតនៅចុងឆ្នាំ ១៩៣២ នូវគណៈកម្មការពេញច្បាប់តូចមួយ នៅក្រុងព្រៃនគរ ។

គណៈកម្មការនោះ មានអង្គការសារពត៌មាន ២ សម្រាប់បំរើឧត្តមគតិរបស់គេ គឺ ៖

- ទង់ក្រហម
- ទស្សនាវដ្តីកុម្មុយនិស្ត

ដូច្នេះ អង្គការកុម្មុយនិស្តឥណ្ឌូចិននេះ ក្លាយទៅជាគណបក្សប្រឆាំងពេញច្បាប់ ។

## III រណសិរ្ស របស់ គណបក្សកុម្មុយនិស្តឥណ្ឌូចិន

ដើម្បីទ្រទ្រង់សកម្មភាព របស់គណបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលរលាយរូបទៅហើយនោះ ពួកកុម្មុយនិស្តយួន បានបង្កើតជា រណសិរ្ស ជាច្រើន ។

### ១. រណសិរ្ស ប្រជាធិបតេយ្យឥណ្ឌូចិន

នៅឆ្នាំ ១៩៣៦ នៅឯប្រទេសបារាំងឯណោះ ពួកកុម្មុយនិស្តបារាំង បានឡើងកាន់អំណាច ក្រោមការដឹកនាំ របស់ ឡេអុង ព្លុម ។ ឡេអុង ព្លុម ក៏បានបង្កើតរណសិរ្សមួយ ឈ្មោះ រណសិរ្ស ប្រជាមានិត (FRONT POPULAIRE) ។

ឆ្លៀតឱកាសដែលពួកកុម្មុយនិស្តបារាំង ឡើងកាន់អំណាចនេះ ពួកកុម្មុយនិស្តយួន ក៏បង្កើតជារណសិរ្សមួយដែរ ដែលមានឈ្មោះជា រណសិរ្ស ប្រជាធិបតេយ្យឥណ្ឌូចិន ។ រណសិរ្ស របស់យួននេះ មានបំណងធំបំផុត គឺធ្វើយ៉ាងណា ឲ្យពួកកុម្មុយនិស្តបារាំង ដោះលែងអ្នកទោសនយោបាយជាតិយួន ដូចជា ង្វៀង អៃកុក, ផាំ វ៉ាន់ដុង ជាដើម ។ ប៉ុន្តែ



រណសិរ្សនេះ ត្រូវរលាយខ្លួនទៅវិញ ជាមួយនឹងរណសិរ្សប្រជាមានិតរបស់បារាំង ។

### ២. រណសិរ្ស ប្រជាមានិតរួម

ឆ្នាំ ១៩៣៩ ជាឆ្នាំដែលបារាំង កំពុងតែជាប់ដៃទប់ជាមួយនឹងអាល្លឺម៉ង់ ក្នុងសង្គ្រាមលោកលើកទី ២ ។ ឆ្លៀតពេលដែលបារាំង កំពុងតែមានបញ្ហាសង្គ្រាមយ៉ាងធំនេះ ពួកកុម្មុយនិស្តយួន ក៏នាំគ្នាបង្កើត រណសិរ្សប្រជាមានិតមួយទៀត ឈ្មោះ រណសិរ្ស ប្រជាមានិតរួម ។ រណសិរ្សនេះ បានរៀបចំធ្វើ បាតុកម្ម, កូដកម្ម និង ធ្វើការបំបះបំបោរផ្សេងៗជាច្រើន ។ បារាំង ដែលកំពុងតែជាប់ដៃធ្វើសង្គ្រាមជាមួយអាឡឺម៉ង់ មិនអាចដោះស្រាយបញ្ហាយួន ដែលបង្កើតឡើងដោយ រណសិរ្សប្រជាមានិតរួមនេះ បានឡើយ ។ អាស្រ័យហេតុនេះហើយ បានជាពួកជនជាតិយួនជាច្រើន ជាពិសេស កម្មករ និង កសិករ នាំគ្នាចូលជាសមាជិក គណបក្សកុម្មុយនិស្តឥណ្ឌូចិន ។

### ៣. រណសិរ្ស យៀកមិញ

ង្វៀង អៃកុក ដែលគេស្មានតែស្លាប់ កាលពីឆ្នាំ ១៩៣២ នៅក្រុងហុងកុងទៅហើយនោះ ក៏បានលេចមកក្នុងឆាកនយោបាយវិញ ដោយផ្លាស់ឈ្មោះជា ហូ ជីមិញ ។ នៅឆ្នាំ ១៩៤១ ហូ ជីមិញ បានកោះហៅសហការីសំខាន់ៗរបស់គាត់ នៅក្នុងគណបក្សកុម្មុយនិស្តឥណ្ឌូចិន ទៅប្រជុំជាសមាជ នៅក្រុងស៊ីនស៊ី នៃ ប្រទេសចិន ។ សមាជនេះក៏បានសំរេចបង្កើតជា រណសិរ្សមួយ ដែលមានឈ្មោះជាអក្សរកាត់ "រណសិរ្សយៀកមិញ" ។ គោលបំណងរបស់គេ គឺ ប្រមូលជនជាតិយួនគ្រប់ជាន់ថ្នាក់ ដើម្បី ៖

- រាតត្បាតលុកលុយ កម្ពុជាក្រោម, ប្រទេសខ្មែរ និង ប្រទេសលាវ ។
- ច្បាំងកំចាត់ បារាំង ហើយនិង ជប៉ុន ។

ដូច្នេះយើងឃើញថា ពួកកុម្មុយនិស្តឥណ្ឌូចិន មានអង្គការប្រយុទ្ធ ខាងនយោបាយផង និង ខាងយោធាផង ។ ដោយសារ រណសិរ្សយៀកមិញនេះ ពួកកុម្មុយនិស្តយួន បានរាតត្បាតពេញប្រទេសទាំងឡាយ នៅឥណ្ឌូចិន "យួន, កម្ពុជាក្រោម, ខ្មែរ, លាវ" ។

ក្រោយមក នៅថ្ងៃទី ២ កញ្ញា ១៩៤៥ ក្រោយដែលជប៉ុនបានប្រកាសចុះចាញ់ ក្នុងសង្គ្រាមលោកលើកទី ២ ហូ ជីមិញ បានប្រកាសឯករាជ្យឲ្យប្រទេសយួន និង ប្រកាសបង្កើតសាធារណរដ្ឋ ប្រជាធិបតេយ្យយួន ។ ចំណែកឯ ព្រះចៅ បៅដាយ សុខចិត្តចុះចេញពីរាជសម្បត្តិ ប្រគល់អំណាចទាំងអស់ ទៅឲ្យ ហូ ជីមិញ ។ ហូ ជីមិញ ក៏តែងតាំង បៅដាយ ជាទីប្រឹក្សាជាន់ខ្ពស់ នៃ សាធារណរដ្ឋ ។ ពេលនោះ ដើម្បីឲ្យមានការគាំទ្រពីប្រទេសចិន, អាមេរិកាំង, អង់គ្លេស... និង ពលរដ្ឋយួនដែលមិនស្រឡាញ់លទ្ធិកុម្មុយនិស្ត

នោះ ហូ ជីមិញ ក៏បានប្រកាសលុបគណបក្សកុម្មុយនិស្តឥណ្ឌូចិនចោល កាលពីខែវិច្ឆិកា ១៩៤៥ ។

**សេចក្ដីសង្កេត :**

ដើម្បីឲ្យ រុស្ស៊ី, ចិនកុម្មុយនិស្ត របស់ ម៉ៅ សេទុង និង "សមមិត្ត" របស់គេ មានការទុកចិត្ត ហូ ជីមិញ បានបង្កើតសមាគមមួយ ជំនួសគណបក្សកុម្មុយនិស្តឥណ្ឌូចិន ។ សមាគមនេះ ឈ្មោះ សមាគមឥណ្ឌូចិន ខាងការសិក្សាលទ្ធិមាក្ស

(ASSOCIATION INDO-CHINOISE POUR LES ETUDES MARXISTES ) ដែលមានសកម្មភាពដូចគណបក្សកុម្មុយនិស្ត ឥណ្ឌូចិន ដដែល ។

ម្យ៉ាងទៀត អ្នកប្រាជ្ញខាងប្រវត្តិសាស្ត្រជាច្រើន គេបានសំគាល់ថា ឆ្នាំ ១៩៤១ គឺជាឆ្នាំដែលសង្គ្រាមឥណ្ឌូចិនទី ១ ចាប់ផ្ដើមផ្ទុះឡើងជាដំបូង ។ ដោយហេតុថា ពួកយៀកមិញ បាន ធ្វើការលុកលុយប្រទេសទាំងឡាយនៅឥណ្ឌូចិន ។

## ៤. រណសិរ្ស លៀចវៀត ១៩៤៦

ខែ មករា ១៩៤៦ ហូ ជីមិញ បានជាប់ឆ្នោតជា ប្រធានាធិបតី នៃ សាធារណរដ្ឋប្រជាធិបតេយ្យយួន ។ ពេលនោះ ហូ ជីមិញ បានរៀបចំធ្វើជា រណសិរ្សបង្រួបបង្រួមជាតិមួយ ឈ្មោះថា "រណសិរ្ស លៀចវៀត" ។ គណបក្សនយោបាយធំៗឯទៀតជាច្រើន បានចូលទៅក្នុងរណសិរ្ស លៀចវៀត នេះផងដែរ ។ ចាប់តាំងពីពេលនោះមក ហើយដែលគេឃើញរដ្ឋាភិបាលរបស់ ហូ ជីមិញ ចាប់ផ្ដើមរៀបចំអនុវត្ត នូវនយោបាយរបស់ខ្លួន ឲ្យស្របទៅតាមកម្មវិធីរបស់គណបក្សកុម្មុយនិស្តឥណ្ឌូចិន គឺ ៖

- ទាមទារ ដីកម្ពុជាក្រោម
- ឯករាជ្យ និង ឯកភាពយួន
- ដេញបារាំង ពីឥណ្ឌូចិន
- ត្រួតត្រាឥណ្ឌូចិន ជំនួសបារាំង

ក្នុងការទាមទារ ដីកម្ពុជាក្រោម នេះ ហូ ជីមិញ បានប្រើកលល្បិចយ៉ាងប៉ិនប្រសប់បំផុត ។ ខ្មែរយើង មិនទាំងដឹងខ្លួនស្រួលបួលផង ហូ ជីមិញ បានចុះហត្ថលេខាលើសេចក្ដីព្រមព្រៀង ជាមួយនឹងបារាំង ចំនួន ៣ លើក រួចជាស្រេចទៅហើយ គឺ ៖ សេចក្ដីព្រមព្រៀងនៅក្រុងហាណូយ ចុះថ្ងៃទី ៦ មិនា ១៩៤៦ (ACCORD DE HANO DU 6 MARS 1946) សេចក្ដីព្រមព្រៀងនេះ ជាលទ្ធផល នៃ ការចរចាយ៉ាងស្វិតស្វាញ រវាង ហូ ជីមិញ



និង បារាំង អំពីបញ្ហា កម្ពុជាក្រោម, ឯករាជ្យ, ឯកភាពយួន ។ល។ សេចក្ដីព្រមព្រៀងក្រុងដាឡាត់ ចុះថ្ងៃទី ២៤ មេសា ១៩៤៦ (ACCORD DE DALAT DU 24 AVRIL 1946) សេចក្ដី ព្រមព្រៀងនេះ ជាលទ្ធផល នៃ សន្និសីទក្រុងដាឡាត់ រវាង គណប្រតិភូ បារាំង និង គណ-ប្រតិភូ យៀកមិញ ស្ដីអំពីការអនុវត្តន៍ នូវសេចក្ដីព្រមព្រៀង ចុះថ្ងៃទី ៦ មិនា ១៩៤៦ ។

សន្ធិសញ្ញាបណ្ដោះអាសន្ន នៅក្រុងហ្វុងតែណប្លូ ចុះថ្ងៃទី ១៤ កញ្ញា ១៩៤៦ (MODUS VIVENDI DU 14 SEPTEMBRE 1946 , FONTAINEBLEAU) ។

សន្ធិសញ្ញាបណ្ដោះអាសន្ននេះ បានមកពីសន្និសីទមួយ យ៉ាងយូរ និង យ៉ាងលំបាក រវាង យួន និង បារាំង ស្ដីអំពីបញ្ហា កម្ពុជាក្រោម, ឯករាជ្យ និង ឯកភាពយួន, បញ្ហាសហព័ន្ធឥណ្ឌូចិន (F D RATION INDOCHINOISE) ។ល។

គួរកត់សំគាល់ថា សេចក្ដីព្រមព្រៀង ឬ សន្ធិសញ្ញាបណ្ដោះអាសន្នទាំង ៣ លើកនេះ សុទ្ធតែជាបញ្ហា ដែលទាក់ទងមកនឹងប្រទេសយើងទាំងអស់ ប៉ុន្តែ គេចុះហត្ថលេខា មិនឲ្យខ្មែរយើងចូលរួមជាមួយផងទេ គឺគេដើរ "ខ្សែរលើ" លើយើងរហូត ។ នេះហើយ ជាកលល្បិចមួយ របស់កុម្មុយនិស្តឥណ្ឌូចិន ក្នុងការរៀបត្រួតត្រាប្រទេសទាំងអស់ នៅឥណ្ឌូចិន ។ មកដល់ត្រង់ណេះ យើងឃើញថា យៀកមិញបានប្រើល្បិចខ្លះទៀត ក្រៅផ្លូវច្បាប់ ។

ម្យ៉ាងទៀត ដោយហេតុថា គោលបំណងរបស់គេខាងលើនេះ មិនបានសំរេច ពួកយួនកុម្មុយនិស្ត ក៏បានចាប់ផ្ដើមវាយបារាំង ចេញមុខមែនទែន តាំងពីថ្ងៃ ១៩ ធ្នូ ១៩៤៦ ។

ក្នុងការប្រយុទ្ធជាមួយបារាំងនេះ រណសិរ្ស លៀចវៀត បានដើរតួយ៉ាងសំខាន់ នៅក្នុងប្រទេសយួន ចំណែកឯពួកយៀកមិញវិញ គេខំប្រឹងប្រែងយ៉ាងសម្បើម នៅកម្ពុជាក្រោម, នៅប្រទេស ខ្មែរ និង លាវ ។

ចម្បាំងរវាង បារាំង និង យួន បានចប់ (ក្រោយដែលបារាំង ចាញ់នៅឌៀនបៀនភូ កាលពីថ្ងៃ ៧ ឧសភា ១៩៥៤) ដោយសន្និសីទក្រុងហ្សឺណែវ ស្ដីអំពីបញ្ហាឥណ្ឌូចិន ដែលបានបញ្ចប់កិច្ចការរបស់ខ្លួន នៅថ្ងៃ ២០ កក្កដា ១៩៥៤ ដោយចែកប្រទេសយួនជា ២ តាមបណ្ដោយខ្សែស្របទី ១៧ ។

គួរកត់សំគាល់ថា បារាំង បានប្រគល់ដីនៅកម្ពុជាក្រោម ឲ្យទៅយួនជាស្ថាពរ នៅឆ្នាំ ១៩៤៩ ។

## IV. សង្គ្រាមឥណ្ឌូចិនទី ១ នៅ ប្រទេសខ្មែរ និង ប្រទេសលាវ

ប្រទេសខ្មែរ ជាគោលដៅមួយធំ របស់ពួកកុម្មុយនិស្តយួន ក្នុងការចង់ត្រួតត្រាឥណ្ឌូចិន ជំនួសបារាំង ។ គណបក្សកុម្មុយនិស្តឥណ្ឌូចិន បានបញ្ជូនក្រុមកុម្មុយនិស្ត ឲ្យមកក្នុងប្រទេសទាំង ២ នេះ តាំងពីឆ្នាំ ១៩៤១ ម៉្លេះ (ឆ្នាំដែល ហូ ជីមិញ បង្កើតរណសិរ្សយៀកមិញ) ។

ប៉ុន្តែ សកម្មភាពយោធាចេញមុខរបស់គេ បានចាប់ផ្តើម ពីឆ្នាំ ១៩៤៧ នៅជុំវិញទន្លេសាប, ប៉ៃលិន, កណ្តាល, តាកែវ, កំពត ។ល។ ក្នុងការដែលគេធ្វើសកម្មភាពយោធានេះ គេខំធ្វើការឃោសនាថា គេបានជួយខ្មែរ ក្នុងការដេញបារាំងឲ្យទៅស្រុកវាវិញ ។ ដោយការប្រសប់ ក្នុងការរើសប្រធានឃោសនានេះ ខ្មែរយើងនៅតាមជនបទនានាខ្លះ បានភ័ន្តច្រឡំជួយពួកយួនកុម្មុយនិស្ត យ៉ាងពេញដៃពេញជើង ។

ឆ្នាំ ១៩៤៨ សត្តិ ៥ យៀកមិញម្នាក់ ឈ្មោះ ង្វៀង ថាន់សឺន ដែលជាអ្នកស្នងការនយោបាយ របស់យៀកមិញ ប្រចាំភូមិភាគណាំបូ (NAM BO ) គឺ តំបន់កម្ពុជាក្រោម បានប្រកាសច្បាំង ជាមួយនឹងប្រទេសខ្មែរយើង ជាផ្លូវការ ។

គួរយើងចែក សកម្មភាពឃោសនារបស់យៀកមិញ នៅក្នុងប្រទេសខ្មែរយើង ជា ២ ដំណាក់ការ គឺ មុនខែវិច្ឆិកា ១៩៥៣ និង ក្រោយខែវិច្ឆិកា ១៩៥៣ ។

- មុនវិច្ឆិកា ១៩៥៣ : យៀកមិញ បានធ្វើសកម្មភាពយោធាទូទៅ ពេញទាំងប្រទេស ជាពិសេស នៅជុំវិញទន្លេសាប និង នៅប៉ៃលិន ។ បានសេចក្តីថា គេមិនទាន់សំរេចយកគោលដៅណា ឲ្យបានច្បាស់លាស់នៅឡើយទេ ។

- លុះដល់ពេលក្រោយ ដែលបារាំងប្រគល់មេបញ្ជាការជាន់ខ្ពស់ នៃ កងទ័ពទាំងមូល មកឲ្យខ្មែរហើយ (គឺ ទ័ពបារាំងបានដកថយទៅស្រុកវិញ) ពួកយៀកមិញ ដែលបានធ្វើការឃោសនាថា មកជួយដេញបារាំងនោះ ក៏បានធ្វើសកម្មភាពសឹកយ៉ាងខ្លាំង នៅក្នុងប្រទេសខ្មែរយើង តំបន់ភាគខាងកើត នៃ ទន្លេមេគង្គ ។ ភស្តុតាង ពីខែ មិនា ដល់ ឧសភា ១៩៥៤ គេវាយ ហើយកាន់កាប់ទីតាំងទ័ពខ្មែរយើងទៅ ។

- វ៉ឺនសៃ, សៀមប៉ាង, បកែវ, ជុំវិញទីរួមខេត្តស្ទឹងត្រែង, ឆ្លូងលើ "ស្រែជេស", ព្រែកទេ ។ល។

តែដោយសារការឆ្លាតវៃ នៃ កងទ័ពជាតិយើង យើងក៏បានវាយរុញច្រានពួកនេះ ឲ្យត្រឡប់ទៅស្រុកវិញទៅ ។ ស្របពេលជាមួយគ្នានេះ សន្និសីទក្រុងហ្សឺណែវ ៥៤ ក៏បានជួយដេញយៀកមិញ ឲ្យចេញពីប្រទេសខ្មែរយើងដែរ ។

ចំណែក នៅប្រទេសលាវវិញ ពួកយៀកមិញ បានធ្វើសកម្មភាព មិនខុសពីប្រទេសខ្មែរយើងប៉ុន្មានទេ ប៉ុន្តែ តាំងពីឆ្នាំ ១៩៤៦ មក រហូតដល់សព្វថ្ងៃ ពួកយៀកមិញ បានកាន់កាប់



ខេត្តលាវខ្លះ ដូចជា ខុង សាលី, សាម នឿ, ខាំ ម៉ុន, សុវណ្ណខេត្ត ជាដើម (មុនឆ្នាំ ១៩៧២) ។

សន្និសីទក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ បានបញ្ចប់ នូវសកម្មភាពយោធាដ៏ចេញមុខ របស់កុម្មុយនិស្ត យួន ឬ ឥណ្ឌូចិន នេះ ។

## V. សង្គ្រាម ឥណ្ឌូចិនទី ២ ឬ រណសិរ្សសេរីភាពជាតិ

សង្គ្រាមឥណ្ឌូចិនទី ១ បានរលត់ទៅវិញ ដោយធ្វើឲ្យពួកកុម្មុយនិស្ត យួន ឬ ឥណ្ឌូចិន បាន សំរេចគោលបំណងខ្លះ មិនបានសំរេចខ្លះ ។

**☛ គោលបំណង ដែលបានសំរេច គឺ :**

- បានដីកម្ពុជាក្រោម ជាស្ថាពរហើយ ។
- ប្រទេសយួន បានឯករាជ្យពេញលេញ ។
- បារាំង ចាកចេញពីឥណ្ឌូចិន ។

**☛ គោលបំណង ដែលមិនទាន់បានសំរេច គឺ :**

- ត្រួតត្រាឥណ្ឌូចិនទាំងមូល ជំនួសបារាំង ។
- ឯកភាព នៃ ជនជាតិយួន ។

ដើម្បីសំរេច នូវគោលបំណងចុងក្រោយនេះ ពួកកុម្មុយនិស្តយួននេះគេត្រូវតែបង្កបង្កើតឲ្យមានសង្គ្រាមឥណ្ឌូចិននេះ ឡើងវិញ ។

សូមបញ្ជាក់ថា នៅឆ្នាំ ១៩៥៥ ហូ ជីមិញ គាត់បានលុប "សមាគមឥណ្ឌូចិន ខាងការសិក្សាមាក្ស" ចោល ហើយបង្កើតគណបក្សមួយឈ្មោះថា "គណបក្សការងារ" ជំនួសវិញ ។ គណបក្សការងារនេះហើយ ដែលជាគណបក្សធំតែមួយ របស់យួនខាងជើង សព្វថ្ងៃនេះ ។

លុះដល់ថ្ងៃ ២០-១២-៦០ គណបក្សការងារនេះ ក៏សំរេចបង្កើតរណសិរ្សមួយ មានឈ្មោះថា "រណសិរ្សសេរីភាពជាតិ" (FRONT NATIONAL DE LIB RATION OU FNL) ដែល យើងធ្លាប់ឲ្យឈ្មោះថា "យៀកកុង" ។

ហូ ជីមិញ បង្កើតរណសិរ្សនេះឡើង ដើម្បីនឹងបង្កាត់សង្គ្រាមឥណ្ឌូចិននេះ ឲ្យឆេះឡើងវិញ ។ សង្គ្រាមនេះហើយ ដែលយើងឲ្យឈ្មោះថា សង្គ្រាមឥណ្ឌូចិនទី ២ នោះ ។

សង្គ្រាមនេះ ដំបូងឡើង ហូ ជីមិញ ធ្វើឲ្យផ្ទុះនៅក្នុងប្រទេស យួនខាងត្បូង និង លាវ ។

បន្ទាប់មក កុម្មុយនិស្តយួនបាន “បោក” សម្តេច សីហនុ ហើយក៏តាំងទ័ពរបស់ខ្លួន នៅក្នុងខេត្តខ្មែរទាំងឡាយ ដែលមានព្រំដែនជាប់នឹងយួន ដោយមានការយល់ព្រមពី សម្តេច សីហនុ ដែលពេលនោះ ធ្វើជាប្រមុខរដ្ឋខ្មែរយើងផង ។ បានសេចក្តីថា យួនកុម្មុយនិស្ត បានច្បាំងជាមួយនឹងខ្មែរយើង តាំងពីថ្ងៃទី ២០-១០-៦០ ម្ល៉េះ តែខ្មែរយើង ហាក់ដូចជាមិនទាន់ដឹងខ្លួនសោះ ។

លុះក្រោយព្រឹត្តិការណ៍ ថ្ងៃ ១៨ មិនា ១៩៧០ សង្គ្រាមឥណ្ឌូចិនទី ២ នេះ ក៏ផ្ទុះឡើងយ៉ាងខ្លាំង ស្របទៅតាមគោលបំណងរបស់កុម្មុយនិស្តយួន ។ ខ្មែរយើងសព្វថ្ងៃ កំពុងទទួលផលវិបាក ចេញពីគំនិតប្លន់ទឹកដី ពីពួកយួននេះ ។

សង្គ្រាមជាមួយអាមេរិកាំងនេះ យួន ក៏មានគំនិតដេញអាមេរិក ជំនួសអាមេរិក ដែរនៅឥណ្ឌូចិននេះ ។

ពេលដែល សម្តេច សីហនុ បានត្រូវសភាទាំងពីរ ទម្លាក់ទីតំណែងពី ប្រមុខរដ្ឋកម្ពុជា នៅថ្ងៃ ១៨ មីនា ១៩៧០ សង្គ្រាមក៏បានផ្ទុះឡើង នៅកម្ពុជា ។

យួនយៀកកុង និង យួនខាងជើង ដែលមានជំរកនៅប៉ែកខាងកើត ប្រទេសខ្មែរ ដោយមានការអនុញ្ញាតពី សម្តេច សីហនុ ពីឆ្នាំមុនៗមក បានបែរកាំភ្លើង លើកទ័ពវាយសំរុកមកលើទ័ពខ្មែរ ក្នុងទឹកដីស្រុកខ្មែរ ដោយយកលេសថា រំដោះ កម្ពុជា ពីចក្រព័ត្រអាមេរិកថ្វាយ សម្តេចសីហនុ ។

## VI **ឥណ្ឌូចិន ធ្លាក់ចូលដៃ កុម្មុយនិស្ត**

សង្គ្រាមកាចសាហាវបានផ្ទុះឡើង ហើយបានមកបញ្ចប់នៅឆ្នាំ ១៩៧៥ ។ នៅឆ្នាំនេះ ប្រទេសទាំងបី នៃ អតីតឥណ្ឌូចិនបារាំងសែស បានធ្លាក់ចូលដៃកុម្មុយនិស្ត ៖

**កម្ពុជា** បានត្រូវ ខ្មែរក្រហម កាន់កាប់នៅថ្ងៃ ១៧ មេសា **វៀតណាម** បានធ្លាក់ នៅថ្ងៃ ៣០ មេសា កាន់កាប់ដោយកុម្មុយនិស្ត ។ នៅឆ្នាំ ១៩៧៦ យួនមានតែមួយគឺ យួនខាងជើង បានលេបយកយួនខាងត្បូង យួនមានឈ្មោះជាផ្លូវការ **សាធារណរដ្ឋ សង្គមនិយមវៀតណាម** ទីក្រុង **ព្រៃនគរ** ក៏បានប្តូរឈ្មោះទៅជាក្រុង **ហូជីមិញ** ។ **ប្រទេសលាវ** ដែលជាប្រទេសមួយ អនុញ្ញាតឲ្យ កុម្មុយនិស្តយួន ដឹកជញ្ជូនទ័ពតាមផ្លូវលំ ហូជីមិញជាច្រើនឆ្នាំមកហើយនោះ ក៏បានធ្លាក់ចូលដៃ កុម្មុយនិស្តលាវ ប៉ៈថេតឡាវ នៅឆ្នាំ ១៩៧៥ នេះដែរ ។ គួរគប្បីរំលឹកដោយសង្ខេបពី ប្រវត្តិសាស្ត្រលាវ ដើម្បីឲ្យដឹងថា កុម្មុយនិស្តលាវ គាំពារដោយកុម្មុយនិស្តយួន ប្រើមធ្យោបាយអ្វីខ្លះ ដើម្បីសម្លាប់រាជវង្សលាវ នោះ ។



### ***សង្ខេប ប្រវត្តិសាស្ត្រ ប្រទេសលាវ***

ប្រទេសលាវ បច្ចុប្បន្ន មានឫសគលពី រាជាណាចក្រ **ឡានសាង** (MILLION D’ L PHANTS) ដែលបានកើតឡើងនៅគ្រិស្តសតវត្សរ៍ទី ១៤ ដោយ ព្រះចៅ ហ្វាង៉ុម ដែលមានខ្សែស្រឡាយតពីព្រះរាជាលាវ បុរាណ ។ **នគរលានជាង** ឬ **ឡានសាង** រីកចំរើនរហូតមកទល់គ្រិស្តសតវត្សរ៍ទី ១៨ តែក្រោយមក រាជាណាចក្រនេះ ត្រូវបែកបាក់ជា ៣ ផ្នែក ដែលចុងក្រោយ ត្រូវបាន សៀម ត្រួតត្រា ។ នៅគ្រិស្តសតវត្សរ៍ទី ១៩ ហ្លួងព្រះបាង បានត្រូវដាក់បញ្ចូលក្នុង **អាណាព្យាបាល បារាំងសែស នៅឥណ្ឌូចិន** ។ ក្រោយបន្តិចមក តំបន់ **ចំប៉ាសាក់** និង **វៀងច័ន្ទន៍** ក៏ត្រូវបានរាប់បញ្ចូលក្នុងអាណាព្យាបាល បារាំងសែស ដែរ ។ បារាំងសែស សំឡឹងឃើញ ប្រទេសលាវ ជារដ្ឋនៅចន្លោះការប្រទាញប្រទង់រវាង ចក្រភពអង់គ្លេស និង ចក្រភពបារាំងសែស ។ នៅក្រោមអាណាព្យាបាលបារាំងសែស វៀងច័ន្ទន៍ ជាថ្មីម្តងទៀត បានក្លាយជា រដ្ឋធានី របស់រដ្ឋបង្រួបបង្រួមរបស់លាវ ។ ឆ្លងកាត់ការកាន់កាប់មួយរយៈខ្លីពីសំណាក់កងទ័ព **ជប៉ុន** ក្នុង **សង្គ្រាមលោកលើកទី ២** រួចមក លាវបានប្រកាសឯករាជ្យ នៅឆ្នាំ ១៩៤៥ ។ ប៉ុន្តែ បារាំងសែស បានត្រឡប់មកកាន់កាប់វិញ រហូតដល់ឆ្នាំ ១៩៥០ គឺពេលដែល បារាំង បានផ្តល់ស្វ័យភាពពាក់កណ្តាលថាជា **រដ្ឋចំណុះឲ្យសហព័ន្ធបារាំងសែស** ។ លាវ បានទទួលឯករាជ្យបរិបូណ៌នៅឆ្នាំ ១៩៥៤ រួចក្លាយជារដ្ឋកាន់របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។ ក្រោមល័ក្ខណ្ឌលើកលែងមួយក្នុង **សន្ធិសញ្ញាទីក្រុងហ្សឺណែវ** បេសកកម្មហ្វឹកហ្វឺនយោធាបារាំង បានដើរតួនាទីគាំទ្រ កងយោធពលភូមិន្ទលាវ ។ នៅឆ្នាំ ១៩៥៩ ក្រសួងការពារជាតិអាមេរិក បានមកជំនួសកងទ័ពបារាំង ក្នុងការគាំទ្រកងយោពលភូមិន្ទលាវ ប្រឆាំងនឹងពួកកុម្មុយនិស្តប៉ៈថេតឡាវ ។

ប្រទេសលាវ ត្រូវបានអូសចូលទៅក្នុងសង្គ្រាមវៀតណាម ហើយ**តំបន់ភាគខាងកើតរបស់លាវត្រូវបានលុកលុយកាន់កាប់ពីសំណាក់ កងទ័ពវៀតណាមខាងជើង** ដែលពួកនេះបានប្រើប្រាស់ ដែនដីលាវជាមូលដ្ឋាន រៀបចំ និង ផ្លូវដឹកជញ្ជូនសព្វាវុធ និង ស្បៀងអាហារ ទៅឲ្យកងទ័ពតទល់នឹងកងទ័ពវៀតណាមខាងត្បូង ។ ជាការឆ្លើយតប អាមេរិកបានបើកយុទ្ធនាការទម្លាក់គ្រាប់បែកប្រឆាំងនឹង វៀតណាមឆាងជើង ដើម្បីគាំទ្រកម្លាំងប្រឆាំងកុម្មុយនិស្តក្នុងប្រទេសលាវ និង គាំទ្រវៀតណាមខាងត្បូង ក្នុងការលុកលុយប្រទេសលាវ ។ សកម្មភាពទាំងនេះ បានបង្កឲ្យមានការធ្វើរដ្ឋប្រហារជាបន្តបន្ទាប់ ហើយទីបំផុត សង្ខ្រាមស៊ីវិលលាវរវាង រាជរដ្ឋាភិបាលលាវ និង ចលនាកុម្មុយនិស្តប៉ៈថេតលាវ បានចាប់ផ្តើម ។ នៅក្នុងសង្គ្រាមស៊ីវិលនេះ កងទ័ពវៀតណាមខាងជើងដែលមាន អាវុធទំនើបៗ និង រថក្រោះ ស្ថិតនៅពីក្រោយខ្នងពួក ប៉ៈថេតឡាវ ។ នៅឆ្នាំ ១៩៦៨ កងទ័ពវៀតណាមខាងជើង បានបើកការវាយប្រហារច្រើនភូមិភាគ មកលើកងយោធពលភូមិន្ទលាវ ជាហេតុធ្វើឲ្យមានការដាក់ពង្រាយទ័ព ទ្រង់ទ្រាយធំមួយ ។ បន្តមក មានការទម្លាក់គ្រាប់បែកទ្រង់ទ្រាយធំ ពីសំណាក់អាមេរិក ដើម្បីកំទេចមូលដ្ឋានទ័ពវៀតណាមខាងជើង ក្នុងប្រទេសលាវ និងដើម្បីកាត់ផ្តាច់ **ផ្លូវលំហូជីមិញ** ។ គេនិយាយថា គ្រាប់បែកអាមេរិក ទម្លាក់នៅប្រទេសលាវ ពីឆ្នាំ ១៩៧១ ដល់ ១៩៧៣ ច្រើនជាងទម្លាក់នៅទូទាំងពិភពលោក ក្នុងកំឡុងសង្គ្រាមលោកលើកទី ២ (គ.ស. ១៩៣៩ ដល់ ១៩៤៥) ទៅទៀត ។ ជាសារុប មានគ្រាប់បែកជាង ២ លានតោន ត្រូវបានទម្លាក់ ។

នៅឆ្នាំ ១៩៧៥ កងកម្លាំងកុម្មុយនិស្តប៉ៈថេតឡាវ ដែលមានការគាំទ្រពី សហព័ន្ធរុស្ស៊ី និង វៀតណាមខាងជើង បានទទួលជ័យជំនះលើ រដ្ឋាភិបាលរាជានិយម ។ ការណ៍នេះ បង្ខំឲ្យ ព្រះចៅ ***ស៊ីស:វ៉ាងវឌ្ឍនា*** (ស្រីស្វាងវឌ្ឍនា) ដាក់រាជ្យ រួចត្រូវបានគេធ្វើគត ក្រោយពីចាប់ព្រះអង្គបាន ។ បន្ទាប់ពីកាន់កាប់ប្រទេសហើយ រដ្ឋាភិបាលប៉ៈថេតឡាវ បានដាក់ឈ្មោះថ្មីឲ្យ ប្រទេសលាវ ថា ***សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាជនឡាវ*** (សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ) និង បានចុះកិច្ចព្រមព្រៀងឲ្យវៀតណាម ដាក់ទ័ព ធ្វើជាទីប្រឹក្សា មើលការខុសត្រូវប្រទេស ។ នៅ ទសវត្សរ៍ ១៩៧០ ឡាវ ត្រូវបាន វៀតណាម បញ្ជាឲ្យកាត់ផ្តាច់ទំនាក់ទំនងជាមួយ សាធារណរដ្ឋ ប្រជាមានិតចិន ដែលកាត់ផ្តាច់ពាណិជ្ជកម្មឡាវ ជាមួយបណ្តាប្រទេសទាំងអស់ លើកលែងតែ វៀតណាម ។ ការគ្រប់គ្រងដោយ វៀតណាម និង ការធ្វើជាសង្គមនិយម បន្តិចម្តងៗ បានត្រូវជំនួស ដោយ ការបន្ធូរបន្ថយការដាក់កំហិតសេដ្ឋកិច្ចនៅទសវត្សរ៍ ១៩៨០ និង ការអនុញ្ញាតឲ្យចូលជា សមាជិកអាស៊ាន នៅឆ្នាំ ១៩៩៧ ។

***៦៨ ជាតិពន្ធុ រស់នៅប្រទេសលាវ***

មកដល់ឆ្នាំ ២០១១ ប្រទេស លាវ ឬ ឡាវ មានប្រជាជន ៦,៤៨ លាននាក់ រស់នៅលើប្រទេស នេះ ដែលមានទំហំផ្ទៃដី ២៣៦ ៨០០ គម$^{២}$ គឺមានដង់ស៊ីតេប្រជាជន ២៧,៤ នាក់/គម$^{២}$ (កម្ពុជា មាន ៧៤ នាក់/គម$^{២}$) ។ តាម ជាតិពន្ធុវិទូ (**ETHNOLOGUE**) ឡាវ មានជាតិពន្ធុ ៦៨ ខុសៗគ្នា រស់ នៅតាមក្រុមធំៗ បី ៖

១- ***ឡាវលុម*** (LAO LUM) = ឡាវ ***វាលទំនាប*** មាន ៦៨% ដែលមានជាតិពន្ធុ ឡាវ ឬ លាវ និង ជាតិពន្ធុ តៃ **TAI** ។ អ្នកទាំងនេះ រស់នៅតាមវាលទំនាប ។

***២- ឡាវធឿង*** (LAO THEUNG) = ឡាវ ***ជំរាលភ្នំ*** មាន ២២% មានជាតិពន្ធុ ខា **KHA** ។ អ្នក ទាំងនេះ ប្រើភាសា ***ខ្មែរ-មន*** នៅក្នុងក្រុមនេះមាន ៣១ ជាតិពន្ធុ ៖ ***KUEMU, PRAY, KRIENG, KHMER***… ។ល។

***៣- ឡាវស៊ុង*** (LAO SUNG) = ឡាវ ***ភ្នំ*** មាន ៩% មានជាតិពន្ធុ ***ម៉ុង HMONG*** និង ***យ៉ាវ YAO*** ឬ ***MIEN*** ។ អ្នកទាំងនេះ ច្រើនរស់នៅតំបន់ ខ្ពស់ ឬ ភ្នំ ។

**ចំពោះ កម្ពុជា ធ្លាក់ចូលដៃ កុម្មុយនិស្តខ្មែរ នេះ** ជាផលផ្លែផ្ការបស់ពួកនេះ ដែលបាន តស៊ូជិត ៤០ ឆ្នាំមុន មកម្ល៉េះ ។ ខ្មែរកុម្មុយនិស្ត ប៉ុល ពត ឬ ខ្មែរក្រហម ប៉ុល ពត បាន ចាត់ទុកថា ថ្ងៃ ១៧ មេសា ១៩៧៥ ជាថ្ងៃជ័យជំនះរបស់បក្សពួកខ្លួន ដែលបានចាប់កំណើត ពីឆ្នាំ ១៩៦០ ។

ចំណែក ខ្មែរកុម្មុយនិស្ត សឺង ង៉ុកមិញ គាំពារដោយ កុម្មុយនិស្តយួន បានចាត់ទុកថា ជ័យជំនះឆ្នាំ ១៩៧៩ ជារបស់បក្សពួកខ្លួនដែរ ដែលមានកំណើតតាំងពីឆ្នាំ ១៩៥១ ដោយ មានការគាំពារពី កុម្មុយនិស្តយួន គ្រប់មធ្យោបាយ មាន យោធា និង នយោបាយ ។

ខ្មែរក្រហម ប៉ុល ពត បានកាន់កាប់ស្រុកខ្មែរចំនួន ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃ ។ នៅថ្ងៃ ៧ មករា ១៩៧៩ ទ័ពយួន ជាមួយខ្មែរក្រហមប្រឆាំងបក្ស ប៉ុល ពត បានវាយផ្តាច់ព្រ័ត្រ



ទម្លាក់របប កម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត ។ តាំងពីឆ្នាំ ១៩៧៩ នោះ បក្សកុម្មុយនិស្ត ដែលដឹកនាំកម្ពុជា មានឈ្មោះថា "បក្សប្រជាជនកម្ពុជា" គឺជាបក្សកុម្មុយនិស្ត ដែលមាន ជីវិតខ្ពស់ទាប មានការវិវត្តន៍តាំងពីឆ្នាំ ១៩៥១ មកម្ល៉េះ ។ មានរបៀបគ្រប់គ្រងជាលក្ខណៈ កុម្មុយនិស្ត បក្សប្រជាជនកម្ពុជា (ប្រ.ជ.ក.) បែងក្រឡាប្រទេសត្រួតត្រាតាំងពីថ្នាក់ ភូមិ ឃុំ ស្រុក ខេត្ត ។ នៅទីណា ក៏មានឃើញរូបថ្នាក់ដឹកនាំ ៣ នាក់ ជា ស៊ីម ហ៊ុន សែន ហេង សំរិន ជារូបឃោសនាកំញើញអ្នកដទៃទៀតឲ្យព្រឺជឿថា មានតែ ប្រ.ជ.ក. មួយ ប៉ុណ្ណោះ ដែលជួយស្រុកខ្មែរឲ្យរស់ ពីរបប ប៉ុល ពត ។

***ព្រំដែនប្រទេស*** ដែលមានពីសម័យអាណាព្យាបាលបារាំង បានត្រូវប្រទេសជិតខាង សើរើឡើង ។ ប៉ែកខាងកើត ព្រំដែនជាមួយវៀតណាម បានត្រូវ ប្រ.ជ.ក. ទទួលយល់ព្រម ឲ្យមានការបោះបង្គោលព្រំដែនជាថ្មី ដែលមានបង្គោលខ្លះ ចូលក្នុងទឹកដីខ្មែរ ។ ប៉ែកខាង លិច ជាមួយសៀមវិញ មានការសើរើជាច្រើនកន្លែង នៅតំបន់ជុំវិញ ប្រាសាទព្រះវិហារ ក៏ សៀមទាមទារទឹកដីចំនួន ៤,៦ គម$^{២}$ ដែរ ។

***នៅក្នុងប្រទេស*** រដ្ឋាភិបាលដឹកនាំដោយ ប្រ.ជ.ក. បានស៊ីញ៉េកុងត្រាធ្វើសម្បទាន ទឹកដី ព្រៃព្រឹក្សា ក្នុងរយៈពេល ៩៩ ឆ្នាំ ឲ្យទៅបរទេសធ្វើអាជីវកម្ម ។

តាមវចនានុក្រម សម្តេច ជួន ណាត (១៩៦៧-៦៨) ***សម្បទាន*** គឺ ***ការប្រគល់ឲ្យ ដល់ដៃ ការឲ្យដាច់*** ។ សម្បទាន មានធ្វើ លើទឹកដីមានព្រៃឈើ លើទីកន្លែងណាមាន ធនធានធម្មជាតិ... មានទាំងធ្វើនៅកណ្តាលក្រុងភ្នំពេញ ទៀតផង ដោយសំអាងថា រដ្ឋ ត្រូវការ ធ្វើការអភិវឌ្ឍន៍ ។

មាត្រា ១ នៃ រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ចែងថា ***"ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រ ដែលមានព្រះមហាក្សត្រ ទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និង តាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស"*** ។ លើការអនុវត្តន៍វិញ មានការផ្ទុយទាំងស្រុង ៖

- ***រដ្ឋសភា*** ដែលមាន ១២៣ អាសនៈ បក្សប្រជាជនមាន ១ ភាគ ៤ នៅ ***ព្រឹទ្ធសភា*** ដែល មាន ៦១ អាសនៈ បក្សប្រឆាំងមាន ១ ភាគ ៥ គ្មានសំឡេងផ្តល់យោបល់ឲ្យរដ្ឋាភិបាល ធ្វើបានឡើយ មានតែគណបក្សនយោបាយកាន់អំណាចគឺ ប្រ.ជ.ក. សំរេចដឹកនាំប្រទេស ម្នាក់ឯង ប្រៀបបីដូចជា រាជាណាចក្រកម្ពុជា ដឹកនាំដោយគណបក្សនយោបាយតែមួយ ដូចជានៅ វៀតណាម ឬក៏ លាវ ដូច្នោះដែរ ដែល***ប្រទេសពីរនេះ ជាប្រទេសកុម្មុយនិស្ត*** ចេញមុខត្រង់ៗ តែម្តង ។

***ការរៀបចំសង្គមវិញ មានភាពអយុត្តិធម៌*** អ្នកមានៗទ្រព្យសម្បត្តិស្តុកស្តម្ភ ឯអ្នកក្រ

វិញ ក្រគោកយ៉ាករហោមរហាមយ៉ាងក្រៃលែង ។

រាជាណាចក្រកម្ពុជា ដែលដឹកនាំដោយពួកកុម្មុយនិស្ត កំពុងលេងល្ខោនបញ្ឆិចបញ្ឆើរ ដោយតាំងខ្លួនថា ជាអ្នកប្រជាធិបតេយ្យសេរីនិយម ។ ទង្វើរបៀបនេះ តើថ្នាក់ដឹកនាំខ្មែរមាននឹកឃើញខ្លាចប្រវត្តិសាស្ត្រដើមវិលត្រឡប់មកវិញ ឬទេ ? ព្រឹត្តិការណ៍ឆ្នាំ ១៩៧៥ បណ្តាលឲ្យ កម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត កាន់កាប់ធ្វើឲ្យខ្មែរស្លាប់ ២ លាននាក់ សៀម និង យួន បានយកទឹកដីខ្មែរអស់មួយភាគធំ ច្បាស់ជាមានមូលហេតុមួយផ្នែក ពីអយុត្តិធម៌សង្គមនេះដែរ ។



ដំណាក់កាលនានានៃការពង្រីកទឹកដីយួន



ការបង្កបង្កើតសហភាពឥណ្ឌូចិន



| ខេត្តខ្មែរនៅកម្ពុជាក្រោម* | | |
|---|---|---|
| ឈ្មោះខ្មែរ | ឈ្មោះយួន [illegible] | ប្រជាជន [illegible] |
| ១-ព្រះត្រពាំង | Travinh (Vinh Binh) | 965 700 |
| ២-ឃ្លាំង | Soc Trang | 1 173 800 |
| ៣-ក្រមួនស-ពាម<br>កោះត្រល់ | Kieng Giang (Rach Gia,Ha Tien)<br>Phu Quoc | 1 494 400 |
| ៤-ពលលាវ | Bac Lieu | 736 300 |
| ៥-ទឹកខ្មៅ | Ca Mau | 1 117 800 |
| ៦-ព្រែកឬស្សី | Can Tho | 1 811 100 |
| ៧-លង់ហោរ | Vinh Long | 1 010 500 |
| ៨-អាចទ្រាក់-មាត់ជ្រូក | Ang Giang(Long Xuyen, Chau Doc) | 2 049 000 |
| ៩-រោងដំរី | Tay Ninh | 965 200 |
| ១០-ព្រៃនគរ | Saigon (Ho Chi Minh Ville) | 5 037 200 |
| ១១-ទួលតាមោក | Thu Du Mot<br>Binh Phuoc | 716 400<br>653 600 |
| ១២- ចង្វាព្រាំងស្រុកត្រែ | Dông Nai(Bien Hoa) | 1 989 500 |
| ១៣- មេស-កោះកុង | Tiền Giang(My Tho,Go Cong) | 1 605 100 |
| ១៤-ព្រះសួគ៌-អូរកាប់ | Baria-Vung Tau (Côn Dao) | 805 600 |
| ១៥-កំពង់ឫស្សី | Bến Tre | 1 296 900 |
| ១៦-កំពង់គោ | Lông An (Tan An) | 1 306 200 |
| ១៧-ផ្សារដែក | Dông Thap (Sa Dec) | 1 565 000 |
| ១៨-កោះត្រឡាច | Con Dao (Con Son) | |
| ប្រជាជនទាំងអស់មាន២៦.២៩៩.៣០០នាក់ ខ្មែរមាន៨លាននាក់គឺ៣៣% | | |

*កម្ពុជាក្រោម [illegible] ២០០៥ [illegible]

# សារិន ឆាក
## (១៩២២ - ១៩៧៩ ?)

លោក សារិន ឆាក កើតនៅថ្ងៃទី ២ ខែមករា ឆ្នាំ ១៩២២ នៅភូមិក្រាំងស្លា ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ ឪពុកឈ្មោះ ឃិន ម្ដាយឈ្មោះ ឆាយ ឡាក់ ។ ឈ្មោះដើមរបស់គាត់ គឺ ឃិន កាំង ។ ប៉ុន្តែ ដើម្បីអាចចូលរៀន មធ្យមសិក្សា បាន កុំឲ្យមានបញ្ហាដោយសារអាយុ លោក ឃិន កាំង បានប្ដូរឈ្មោះមកជា សារិន ឆាក វិញ ឈ្មោះដែលគេស្គាល់គាត់ មកដល់សព្វថ្ងៃ ។ ពេលដែលចេញពី សាលាភូមិន្ទរដ្ឋបាល គាត់បានត្រូវតែង-តាំងជា ឧត្តមមន្ត្រី បំរើការនៅ សាលាក្រុងភ្នំពេញ បន្ទាប់មក នៅ ក្រសួងការបរទេស ។ ព្រមពេលជាមួយគ្នា គាត់បានចូលសិក្សានៅ មហាវិទ្យាល័យច្បាប់ និង វិទ្យាសាស្ត្រសេដ្ឋ-កិច្ច ក្រុងភ្នំពេញ ។ បន្ទាប់ពីបានទទួល បរិញ្ញាប័ត្រច្បាប់ គាត់បានបន្តការងារធ្វើការស្រាវ-ជ្រាវ ព្រំដែនកម្ពុជា នៅស្រុកបារាំង ។ នៅទសវត្ស ៦០ លោក សារិន ឆាក ត្រូវបានតែង-តាំងជា នាយក គ្រឹស្ថានកម្ពុជា (***MAISON DU CAMBODGE***) នៅ បុរីសាកលវិទ្យាល័យអន្តរជាតិ ក្រុងប៉ារីស និង ជា អគ្គរាជទូតកម្ពុជា ប្រចាំយូណេស្កូ ។ នៅឆ្នាំ ១៩៦៦ លោក សារិន ឆាក បានការពារនិក្ខេបបទ បណ្ឌិតវិទ្យាសាស្ត្រនយោបាយ “ព្រំដែន នៃ ប្រទេសកម្ពុជា” (និក្ខេបបទនេះ មានបកប្រែជាភាសាខ្មែរ បោះពុម្ពផ្សាយនៅភ្នំពេញ ឆ្នាំ ២០០៤) ។ នៅឆ្នាំ ១៩៦៧ គាត់ត្រូវបានតែងតាំងជា អគ្គរាជទូតខ្មែរ នៅក្រុងគែ ប្រទេសអេហ្ស៊ីប ។

បន្ទាប់ពីព្រឹត្តិការណ៍ ឆ្នាំ ១៩៧០ លោក សារិន ឆាក បានជ្រើសរើសផ្លូវដើរតាមសម្ដេច សីហនុ ។ គាត់បានចូលជា សមាជិក រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា (***FUNK***) និង ជា រដ្ឋមន្ត្រី ការបរទេស របស់ រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា (***GRUNK***) រហូតដល់ថ្ងៃទី ១៩ កក្កដា ១៩៧៥ ។ បន្ទាប់ពីខ្មែរក្រហមទទួលជ័យជំនះ គាត់បានវិលត្រ-ឡប់ទៅភ្នំពេញ ។ គាត់បានត្រូវខ្មែរក្រហមចាប់ដាក់គុកបឹងត្របែក ទទួលការអប់រំឲ្យក្រហមឆ្អិនឆ្អៅ ។ បន្ទាប់ពីការទទួលឲ្យមាន នីតិសម្បទា វិញ គាត់បានវិលមកធ្វើការនៅក្រសួងការបរទេស ឆ្នាំ ១៩៧៨ ។ លោក សារិន ឆាក បានបាត់ខ្លួនរហូតមក បន្ទាប់ពីមានការឈ្លានពានទ័ពយួន នៅឆ្នាំ ១៩៧៩ ៕





ផែនទីៈ ទី១-ការបាត់បង់ទឹកដីដែលបណ្តាលមកដោយកម្ពុជា



3 (Titre 2) ផែនទី  សហភាពឥណ្ឌូចិន១៨៨៧





7 (Titre5) ផែនទីភ្ជាប់កន្លែងដាំបង្គោលព្រំដែន  ៥៨-១២៨



11 (Titre 6) ផែនទីព្រំដែនកម្ពុជា-កូសាំងស៊ីនតាមសារាចររបស់  Brévié

